Australian Government
Department of Health

NATIONAL BOWEL CANCER SCREENING PROGRAM

<<ID number>>

**Khmer | ភាសាខ្មែរ**

<<Date>>

<<Name>>
<<Address 1>>
<<Address 2>>

គោរពជូន << Name>>,

## ការជូនដំណឹងអំពីលទ្ធផល

សូមអរគុណចំពោះការចូលរួមក្នុងកម្មវិធីពិនិត្យរកមើលជំងឺមហារីកពោះវៀនថ្នាក់ជាតិ ដោយការប្រគល់សំណាករបស់អ្នកមកវិញសម្រាប់ការធ្វើតេស្ត។

**លទ្ធផលតេស្តរបស់អ្នកគឺ 'វិជ្ជមាន'។ នេះមានន័យថាគេបានរកឃើញឈាមនៅក្នុងសំណាកមួយ ឬសំណាកទាំងពីររបស់អ្នក។**

អាចមានហេតុផលជាច្រើនដែលការរកឃើញឈាម ភាគច្រើនមិននាក់ទងនឹងជំងឺមហារីកទេ។ វាជាការសំខាន់ក្នុងការស្វែងរកមូលហេតុនៃការហូរឈាម។ សូមណាត់ជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នកឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីពិភាក្សាអំពីលទ្ធផលរបស់អ្នក។

ប្រសិនបើអ្នកបានតែងតាំងវេជ្ជបណ្ឌិត ឬមន្ទីរអ្នកជំនាញពិនិត្យព្យាបាលរោគនៅលើទម្រង់បែបបទដែលអ្នកបានផ្ញើជាមួយសំណាករបស់អ្នក លទ្ធផលតេស្តរបស់អ្នកក៏ត្រូវបានផ្ញើទៅពួកគេផងដែរ។

វេជ្ជបណ្ឌិតរបស់អ្នកអាចណែនាំអ្នកឱ្យទៅជួបវេជ្ជបណ្ឌិតពេទ្យឯកទេស ដើម្បីធ្វើនីតិវិធីមួយហៅថាការឆ្លុះមើលពោះវៀនធំ។ វេជ្ជបណ្ឌិតរបស់អ្នកនឹងផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីអត្ថប្រយោជន៍ និងហានិភ័យនៃការឆ្លុះមើលពោះវៀនធំ ហើយអាចឆ្លើយសំណួរណាមួយដែលអ្នកមាន។ ព័ត៌មានក៏ត្រូវបានផ្តល់ជូននៅក្នុងខិត្តប័ណ្ណដែលភ្ជាប់មកជាមួយផងដែរ។

ប្រសិនបើអ្នកមានសំណួរណាមួយ សូមចូលមើលគេហទំព័រ **www.health.gov.au/nbcsp**។ អ្នកក៏អាចហៅទូរសព្ទទៅលេខ **1800 627 701** ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង 8.00 ព្រឹក ដល់ម៉ោង 6 ល្ងាច (លើកលែងតែថ្ងៃឈប់សម្រាកសាធារណៈ)។

ដោយសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រ

<<Authorising Pathologist>>
រោគវិទូដែលមានការអនុញ្ញាត
ក្រុមហ៊ុនរោគសាស្ត្រ Sullivan Nicolaides Pathology Pty Ltd